J Trust Royal Bank

# សេវាកម្មធនាគារតាមអ៊ីនធើណិត ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

ប្រតិបត្តិការធនាគារដោយសាមញ្ញ និង ងាយស្រួលនៅលើម្រាមដៃលោកអ្នក
គ្រប់ពេលវេលា គ្រប់ទីកន្លែង

# សំណួរដែលសួរញឹកញាប់លេខសម្ងាត់ម្តង (OTP)



2019 All rights reserved

J Trust Royal Bank

### តើអ្វីទៅជា OTP៖

OTP តំណាងឱ្យលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ។ នេះគឺជាលេខកូដសុវត្ថិភាព ៦ ខ្ទង់ដែលត្រូវបានផ្ញើទៅកាន់លេខទូរសព្ទចល័តរបស់លោកអ្នកដែលបានចុះឈ្មោះនៅធនាគារ។ នេះគឺជាកម្រិតសុវត្ថិភាពបន្ថែមដើម្បីការពារលោកអ្នកជារៀងរាល់ពេលលោកអ្នកប្រើប្រាស់សេវាកម្មធនាគារតាមអ៊ីនធើណិត។ នេះគឺជាលេខកូដបណ្តោះអាសន្នដែលនឹងផុតសុពលភាពក្នុងរយៈពេល៣០វិនាទីបន្ទាប់ពីលោកអ្នកទទួលបានវា។

### តើនៅពេលណាដែលខ្ញុំប្រើប្រាស់លេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP៖

លោកអ្នកនឹងត្រូវប្រើប្រាស់លេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP សម្រាប់ប្រតិបត្តិការដូចខាងក្រោម៖

- នៅពេលលោកអ្នកប្រតិបត្តិការមុខងារណាមួយ ឬ ប្រតិបត្តិការដែលមានកម្រិតសុវត្ថិភាពណាមួយដូចជាការផ្លាស់ប្តូរលេខសម្ងាត់
- ភ្លេចលេខសម្ងាត់ និង លេខសម្ងាត់ផុតសុពលភាព
- ភ្លេចអត្តសញ្ញាណអ្នកប្រើប្រាស់
- ការចុះឈ្មោះដោយខ្លួនឯង
- ប្រតិបត្តិការនៅក្នុងធនាគារ ប្រតិបត្តិការក្នុងស្រុក និង ប្រតិបត្តិការអន្តរជាតិ
- ការទូទាត់បណ្ណឥណទាន
- ការទូទាត់វិក្កយបត្រ
- ការស្នើសុំសៀវភៅមូលប្បទានបត្រ ការស្នើសុំមូលប្បទានប័ត្រធនាគារ
- ការផ្លាស់ប្តូរកម្រិតបណ្ណឥណពន្ធ
- ការប្តូរបណ្ណ ការបិទបណ្ណ និង ការបើកឱ្យដំណើរការបណ្ណឡើងវិញ
- ការកែប្រែកម្រិតប្រតិបត្តិការ

### តើខ្ញុំនៅតែត្រូវការ token ដើម្បីចូលដំណើរការសេវាកម្មធនាគារតាមអ៊ីនធើណិតឬទេ?

ទេ។ Token ដែលលោកអ្នកកំពុងប្រើប្រាស់នឹងអស់សុពលភាព។ ហើយវានឹងជំនួសមកវិញនូវលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ (OTP) ដែលត្រូវផ្ញើសារទៅកាន់លេខទូរសព្ទចល័តរបស់លោកអ្នកដែលបានកំណត់។ ការអនុវត្តបែបនេះនៅតែអាចផ្តល់ជូនលោកអ្នកនូវសុវត្ថិភាពដដែល ដែលមានដូចបច្ចុប្បន្នដោយមិនចាំបាច់យក token ទៅតាមខ្លួន។

### តើខ្ញុំអាចទទួលបានលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP តាមអ៊ីម៉ែលជំនួសឱ្យសារដែរឬទេ?

ទេ។ លោកអ្នកអាចទទួលបានលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP តាមលេខទូរសព្ទចល័តរបស់លោកអ្នកដែលបានចុះឈ្មោះតែប៉ុណ្ណោះ។

### ចុះប្រសិនបើខ្ញុំនៅបរទេស និង មិនអាចទទួលសារនៃលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP?

ប្រសិនបើលោកអ្នកធ្វើដំណើរទៅបរទេស ហើយលោកអ្នករំពឹងនឹងចូលដំណើរការសេវាកម្មធនាគារតាមអ៊ីនធើណិតកំឡុងពេលនេះ សូមណែនាំលោកអ្នកឱ្យប្រើសេវា roaming អន្តរជាតិដើម្បីទទួលបានសារ។

J Trust Royal Bank

**ខ្ញុំមានទាំងទូរសព្ទ IOS និង កុំព្យូទ័របន្ទះ tablet ។ តើខ្ញុំអាចទទួលបានសារនៃលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP តាមឧបករណ៍ទាំងពីរដែរឬទេ?**

ទេ។លេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP អាចផ្ញើទៅកាន់លេខលេខទូរសព្ទចល័តរបស់លោកអ្នកដែលបានចុះឈ្មោះតែប៉ុណ្ណោះ។

**ខ្ញុំមានទាំងទូរសព្ទ Android និង កុំព្យូទ័របន្ទះ tablet ។ តើខ្ញុំអាចទទួលបានសារនៃលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP តាមឧបករណ៍ទាំងពីរដែរឬទេ?**

ទេ។លេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP អាចផ្ញើទៅកាន់លេខលេខទូរសព្ទចល័តរបស់លោកអ្នកដែលបានចុះឈ្មោះតែប៉ុណ្ណោះ។

**តើខ្ញុំគួរតែធ្វើដូចម្តេចប្រសិនបើខ្ញុំបាត់ទូរសព្ទរបស់ខ្ញុំដែលមានលេខទូរសព្ទបានចុះឈ្មោះ?**

លោកអ្នកគួរតែទាក់ទងធនាគារដោយអញ្ជើញទៅកាន់សាខាណាមួយ ឬ ទូរសព្ទទៅកាន់ផ្នែកសេវាកម្មបំរើអតិថិជនរបស់យើងខ្ញុំតាមរយៈទូរសព្ទលេខ ០២៣ ៩៩៩ ០០០ ដើម្បីធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់លោកអ្នកដែលបានចុះឈ្មោះ។

**ខ្ញុំបានបាត់ទូរសព្ទរបស់ខ្ញុំដែលមានលេខទូរសព្ទចុះឈ្មោះ ហើយឥឡូវនេះខ្ញុំមានលេខទូរសព្ទថ្មី។ តើខ្ញុំគួរផ្តល់ព័ត៌មានថ្មីបំផុតនេះដោយរបៀបណា?**

លោកអ្នកអាចទាក់ទងធនាគារដោយអញ្ជើញទៅកាន់សាខាណាមួយ ឬ ទូរសព្ទទៅកាន់ផ្នែកសេវាកម្មបំរើអតិថិជនរបស់យើងខ្ញុំតាមរយៈទូរសព្ទលេខ ០២៣ ៩៩៩ ០០០។

**ខ្ញុំបានចុះឈ្មោះលេខទូរសព្ទថ្មីជាមួយធនាគារ។ តើរយៈពេលប៉ុន្មានមុនពេលខ្ញុំអាចចូលដំណើរការសេវាកម្មធនាគារតាមអ៊ីនធើណិតដោយប្រើប្រាស់លេខទូរសព្ទថ្មីដើម្បីទទួលបានសារលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះOTP?**

លេខទូរសព្ទចល័តរបស់លោកអ្នកដែលបានចុះឈ្មោះថ្មីនឹងត្រូវបានទទួលស្គាល់ភ្លាមៗ។ ដូច្នេះ លោកអ្នកនឹងអាចចូលដំណើរការសេវាកម្មធនាគារតាមអ៊ីនធើណិតបន្ទាប់ពីយើងខ្ញុំធ្វើធ្វើបច្ចុប្បន្នភាពព័ត៌មានលោកអ្នក។

**តើខ្ញុំគួរធ្វើដូចម្តេចជាមួយ Token របស់ខ្ញុំ?**

ដោយសារតែលោកអ្នកមិនត្រូវការ token នេះដើម្បីចូលដំណើរការសេវាកម្មធនាគារតាមអ៊ីនធើណិតទៀតទេ លោកអ្នកអាចបោះបង់វាចោលបន្ទាប់ពីការផ្លាស់ប្តូរ។

**ហេតុអ្វីបានជាខ្ញុំគួរតែជឿជាក់លេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP?**

លេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP គឺជាការអនុវត្តសុវត្ថិភាពស្តង់ដារសកល។ វាគឺជាមធ្យោបាយដែលមានសុវត្ថិភាពបំផុតដើម្បីប្រាកដថាគណនីធនាគារ និង ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកត្រូវបានការពារ។ នេះគឺជាភាពចាំបាច់ដែលលោកអ្នកត្រូវថែរក្សាការសម្ងាត់ព័ត៌មានបញ្ជាក់អត្តសញ្ញាណសម្រាប់ចូលដំណើរការដូចជាអត្តសញ្ញាណអតិថិជន លេខសម្ងាត់ និង លេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះOTP ។

**តើខ្ញុំគួរធ្វើដូចម្តេចនៅពេលខ្ញុំទទួលបានលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP?**

លោកអ្នកគួរតែបញ្ចូលលេខកូដសម្ងាត់ម្តងចំនួន៦ខ្ទង់ភ្លាមៗទៅក្នុងសេវាកម្មធនាគារតាមអ៊ីនធើណិតមុនពេលផុតសុពលភាព។

**ចុះប្រសិនបើលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP មិនដំណើរការ ឬ ផុតសុពលភាព? តើខ្ញុំអាចទទួលបានលេខកូដម្តងទៀតបានដែរឬទេ?**

បាទ / ចាស។ អ្វីដែលលោកអ្នកត្រូវធ្វើគឺត្រឡប់ក្រោយទៅកាន់ការចុះឈ្មោះដោយខ្លួនឯង និង ចុចលើប៊ូតុង ‘ផ្ញើលេខសម្ងាត់ម្តងសារជាថ្មី’។

**ប្រសិនបើខ្ញុំទទួលបានសារលេខសម្ងាត់ដែលប្រើប្រាស់ម្តងតែប៉ុណ្ណោះ OTP តាមទូរសព្ទចល័តរបស់ខ្ញុំ ហើយខ្ញុំមិនបានចូលដំណើរការសេវាកម្មធនាគារតាមអ៊ីនធើណិត។ តើខ្ញុំគួរធ្វើដូចម្តេច?**

នេះមិនគួរជាករណីដែលកើតឡើងឡើយ លោកអ្នកគួរតែទាក់ទងធនាគារភ្លាមៗដោយអញ្ជើញទៅកាន់សាខាណាមួយ ឬ ទូរសព្ទទៅកាន់ផ្នែកសេវាកម្មបំរើអតិថិជនរបស់យើងខ្ញុំតាមរយៈទូរសព្ទលេខ ០២៣ ៩៩៩ ០០០។